2

# ដំណើរការស្តង់ដារដើម្បីទទួលបានលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់




**ខ្លឹមសារការងារបញ្ជាក់គម្រោងប្លង់គ្រឿងផ្គុំសំណង់របស់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ :**

1. ត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ថាគម្រោងប្លង់គ្រឿងផ្គុំសំណង់ត្រូវបានសិក្សាស្របតាមគម្រោងប្លង់ស្ថាបត្យកម្មដែលត្រូវបានយល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ច។

2. ត្រួតពិនិត្យនិងប្រើប្រាស់បទប្បញ្ញត្តិបច្ចេកទេសសំណង់បទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធក្នុងការសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់។

3. ត្រួតពិនិត្យនិងប្រើប្រាស់បទប្បញ្ញត្តិបច្ចេកទេសសំណង់ស្តង់ដារកម្ពុជា បទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់សម្ភារៈសំណង់និងផលិតផលសំណង់ក្នុងការសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់។

4. យល់ដឹងពិការសន្មត ដែនកំណត់ និងក្បួនគណនានៃកម្មវិធីកុំព្យូទ័រដែលបានប្រើប្រាស់សម្រាប់ការបង្កើតគំរូ ការវិភាគនិងការគណនាគ្រឿងផ្គុំសំណង់។

5. បង្កើតគំរូគ្រឿងផ្គុំ វិភាគ និងគណនាដោយឯករាជ្យដើម្បីកំណត់ភាពគ្រប់គ្រាន់ និងភាពធន់រឹងមាំនៃរាល់សមាសភាពគ្រឿងផ្គុំសំណង់ដោយគិតទាំងគ្រឿងផ្គុំផ្នែកខាងក្រោម និងគ្រឿងផ្គុំផ្នែកខាងលើ។

6. ផ្ទៀងផ្ទាត់ការកំណត់ ការគណនា និងការជ្រើសរើសបន្ទុកគណនា។

7. ផ្ទៀងផ្ទាត់វិធីសាស្ត្រនិងលទ្ធផលនៃការវិភាគគ្រឿងផ្គុំសំណង់។

8. ផ្ទៀងផ្ទាត់លក្ខខណ្ឌនិងការគណនាសមាសភាពនៃគ្រឿងផ្គុំសំណង់។

9. ផ្ទៀងផ្ទាត់ថា ភាពដាប ភាពរេ ភាពស្រុត ភាពវិល ភាពញ័រនិងស្នាមប្រេះ នៃគ្រឿងផ្គុំសំណង់ ស្ថិតក្នុងដែនកំណត់នៃបទប្បញ្ញត្តិបច្ចេកទេសសំណង់ បទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធ។

10. ផ្ទៀងផ្ទាត់ថាប្លង់លម្អិតគ្រឿងផ្គុំសំណង់ បានបញ្ចូលនូវទិដ្ឋភាពទាំងអស់នៃការគណនាគ្រឿងផ្គុំ។

11. ត្រួតពិនិត្យថាប្លង់គ្រឹះនៃសំណង់ ត្រូវបានសិក្សាអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ បទដ្ឋានបច្ចេកទេស គោលការណ៍ណែនាំបច្ចេកទេស និងការពិសោធន៍ពាក់ព័ន្ធនឹងបច្ចេកទេសភូគព្ភសាស្ត្រ ការសិក្សាអង្កេតដី ការគ្រឹះ ការពិសោធន៍លទ្ធភាពទ្រទ្រង់របស់សសរគ្រឹះ។ ពិសោធន៍គុណភាពសសរគ្រឹះ។

12. ផ្ទៀងផ្ទាត់ថាស្ថិរភាពនៃគ្រឿងផ្គុំសំណង់ សមស្របតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ស្តង់ដាកម្ពុជា បទដ្ឋានបច្ចេកទេសនិងគោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធ។

13. ចំពោះគ្រឿងផ្គុំខ្ពស់ ត្រូវពិនិត្យដល់ភាពចាំបាច់នៃការវិភាគឌីណាមិកសម្រាប់បន្ទុកដែលគិតបញ្ចូលក្នុងការគណនា បន្ទុកខ្យល់ បន្ទុករញ្ជួយដីក្នុងករណីបើមាន។

14. ត្រួតពិនិត្យការសិក្សាគម្រោងប្លង់និងសេចក្តីណែនាំបច្ចេកទេសក្នុងការដំឡើងប្រព័ន្ធជញ្ជាំងទប់ដីសម្រាប់សាងសង់គ្រឿងផ្គុំផ្នែកខាងក្រោម។

15. ត្រួតពិនិត្យសមាសភាពនៃគ្រឿងផ្គុំសំណង់បណ្តោះអាសន្ននិងអចិន្ត្រៃទាំងឡាយដែលបានសាងសង់ឡើង ដើម្បីធានាមិនអោយប៉ះពាល់ដល់សំណង់ជិតខាង។

## ② សេវាបញ្ជាក់គម្រោងប្លង់គ្រឿងផ្គុំសំណង់ដើម្បីស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់

### ការជួបប្រជុំជាមុន

សូមពិនិត្យមើល「មូលដ្ឋាននៃដំណើរការដើម្បីទទួលបានលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់」។

※ ឯកសារដែលតម្រូវអោយម្ចាស់សំណង់ដាក់មកមានដូចខាងក្រោម។

| | | |
|---|---|---|
| O-5 | លិខិតប្រគល់ និងទទួលឯកសារបច្ចេកទេស | ២ច្បាប់ |
| O-6 | លិខិតប្រគល់សិទ្ធិ | ១ច្បាប់ |
| O-7 | កិច្ចសន្យា | ២ច្បាប់ |

O-8 ឯកសារបច្ចេកទេស

O-8①លិខិតអនុញ្ញាតសាងសង់ ថតចម្លងជាឯកសាររឹង ១ច្បាប់ និង PDF

O-8②ប្លង់ស្ថាបត្យកម្ម ដែលទទួលបានការអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



Address: Lot No. 2005, Office No. 515, 5th Floor, Street 307, Sangkat Khmuonh, Khan Sen Sok, Phnom Penh, Cambodia.

- ប្លង់ទិដ្ឋភាពទូទៅ (Master Plan) ថតចម្លងជាឯកសាររឹង ១ច្បាប់ និង PDF
- ប្លង់បាតគ្រប់ជាន់, ប្លង់មុខភាព, ប្លង់ពំនុះកាត់ (Layout Plan, View & Section Plan) ថតចម្លងជាឯកសាររឹង ១ច្បាប់ និង PDF

O-8③របាយការណ៍ស្តីពីការត្រួតពិនិត្យ និងបញ្ជាក់គ្រោងប្លង់ស្ថាបត្យកម្ម ថតចម្លងជាឯកសាររឹង ១ច្បាប់ និង PDF

O-8④លិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់ស្ថាបត្យកម្ម ថតចម្លងជាឯកសាររឹង ១ច្បាប់ និង PDF

O-8⑤រូបភាពនេត្រាទស្សន៍ (3D Views or Perspective View) ជាឯកសាររឹង ១ច្បាប់ និង PDF

O-8⑥គ្រោងប្លង់គ្រឿងផ្គុំសំណង់ (Structural Plan) មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម ៦ច្បាប់ និង ជាឯកសារអេឡិចត្រូនិក AutoCAD & PDF

O-8⑦សេចក្តីណែនាំ ឬបទដ្ឋានបច្ចេកទេស (Technical Specification or General Notes) មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម ១ច្បាប់ និង PDF

O-8⑧សៀវភៅបន្ទុកនៃការសាងសង់ និងកូដសិក្សាគ្រឿងផ្គុំ (Design Loads Standard and Design Code) មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម ១ច្បាប់ និង PDF

O-8⑨របាយការណ៍ស្តីពីការអង្កេតដី (Geotechnical or Soil Investigation) មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម ១ច្បាប់ និង PDF

O-8⑩របាយការណ៍ស្តីពីការគណនា (Calculation Note) មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម ១ច្បាប់ និង PDF

O-8⑪ឯកសារគំរូតម្លើងសិក្សាគ្រឿងផ្គុំ (Structural Modeling File) មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម ១ច្បាប់ និងជាឯកសារអេឡិចត្រូនិក

O-8⑫ប្លង់ និងសេចក្តីណែនាំបច្ចេកទេសក្នុងការតម្លើងប្រព័ន្ធជញ្ជាំងទប់ដីបណ្តោះអាសន្ន (Temporary Retaining Wall drawing and Method Statement) មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម ៦ច្បាប់ និង ឯកសារអេឡិចត្រូនិក AutoCAD & PDF

O-8⑬របាយការណ៍គណនាបន្ទុកជញ្ជាំងទប់ដីបណ្តោះអាសន្ន (Temporary Retaining Wall Plan and Calculation Note) មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម ១ច្បាប់ និង PDF

O-8⑭ប្លង់សមាសភាគនៃគ្រឿងផ្គុំសំណង់បណ្តោះអាសន្ន និងអចិន្ត្រៃយ៍ (Mobilization Plan drawing) មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម ៦ច្បាប់ និង ឯកសារអេឡិចត្រូនិក AutoCAD & PDF

O-8⑮Wind Tunnel Testing Report មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម ១ច្បាប់ និង PDF

* ចំណុច O-8 ⑤ ⑪ ⑬ សូមភ្ជាប់មកជាមួយនឹងឯកសារច្បាប់ដើម ឯកសារអេឡិចត្រូនិក Auto CAD និង PDF ។

＊ចំណុច O-8⑥⑦⑧⑨⑩⑫⑭ សូមភ្ជាប់មកជាមួយនឹងឯកសារច្បាប់ដើម ឯកសារអេឡិចត្រូនិក PDF ។

*ចំណុច O-8①②③④ សូមភ្ជាប់មកជាមួយនឹងឯកសារអេឡិចត្រូនិក PDF ។

① ការទទួល （ទទួលតាមរយៈតេលេក្រាមតែប៉ុណ្ណោះ）

ក្នុងករណីធ្វើការស្នើសុំផ្តល់សេវាពីក្រុមហ៊ុនយើងខ្ញុំ សូមធ្វើការបំពេញឯកសារ (ដែលទាញយកពីតំណរGoogle Drive) និងចុះហត្ថលេខា រួចផ្ញើរមកក្រុមហ៊ុនរបស់យើងខ្ញុំតាមរយៈតេលេក្រាមដោយ [ម្ចាស់សំណង់ ឬអ្នកទទួលសិទ្ធិ]។

យើងនឹងទទួលឯកសារដែលប្រគល់មកដូចខាងក្រោម។

O-1 លិខិតទទួលអតិថិជន （ព័ត៌មានរបស់ម្ចាស់សំណង់, អ្នកសិក្សាគម្រោងប្លង់, ប្រភេទនៃការបញ្ជាក់, ផ្សេងៗ） ១ច្បាប់

O-2 ព័ត៌មានគម្រោង (ឈ្មោះគម្រោង, អាស័យដ្ឋាន, ផ្ទៃក្រឡា, តំបន់ប្រើប្រាស់, ការប្រើប្រាស់អគារ, ផ្ទៃក្រឡាអគារ, ប្រភេទគ្រឿងផ្គុំ) ១ច្បាប់

O-6 លិខិតប្រគល់សិទ្ធ ១ច្បាប់

• ប្លង់ Layout Plan, Floor Plan, Elevation Plan, Section Plan ១ឈុត

② យើងខ្ញុំនឹងធ្វើការជូនដំណឹងវិញអំពី [លិខិតឆ្លើយតបទៅនឹងការផ្តល់សេវា] តាមរយៈតេលេក្រាម។ (ចំណាយពេល៥ថ្ងៃនៃថ្ងៃធ្វើការក្នុងការឆ្លើយតប)

③ ក្នុងករណីធ្វើការស្នើសុំការផ្តល់សេវា សូមធ្វើការដាក់ [លិខិតស្នើសុំផ្តល់សេវា] មកយើងខ្ញុំតាមរយៈតេលេក្រាមក្នុងរយៈពេល៥ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានការជូនដំណឹងពី [លិខិតឆ្លើយតបទៅនឹងការផ្តល់សេវា] ពីខាងក្រុមហ៊ុន។ （ក្នុងករណីបើលិខិតស្នើសុំផ្តល់សេវាមិនត្រូវបានដាក់មកក្នុងរយៈពេល៥ថ្ងៃនោះទេ ការទទួលនឹងត្រូវផុតសុពលភាព）

④ បន្ទាប់ពីដាក់លិខិតស្នើសុំផ្តល់សេវារួច សូមពិនិត្យមើលតារាងឯកសារដែលត្រូវការក្នុងការងារបញ្ជាក់ ។ នៅពេលលោកអ្នកបានរៀបចំឯកសារបានរួចរាល់ សូមធ្វើការណាត់ជួបជាមួយខាងក្រុមហ៊ុនដើម្បីយកឯកសារដែលតម្រូវមកដាក់នៅក្រុមហ៊ុនរបស់យើងខ្ញុំ។

＊តារាងឯកសារត្រូវដាក់

សូមដាក់ឯកសារដូចខាងក្រោម។

| | | |
|---|---|---|
| O-5 | លិខិតប្រគល់ និងទទួលឯកសារបច្ចេកទេស ច្បាប់ដើម (ឧបសម្ព័ន្ធ) | ២ច្បាប់ ហត្ថលេខាដោយម្ចាស់សំណង់ |
| O-6 | លិខិតប្រគល់សិទ្ធិ ច្បាប់ដើម | ១ច្បាប់ ហត្ថលេខាដោយម្ចាស់សំណង់ |
| O-7 | កិច្ចសន្យា ច្បាប់ដើម | ២ច្បាប់ ហត្ថលេខាដោយម្ចាស់សំណង់ |



Address: Lot No. 2005, Office No. 515, 5th Floor, Street 307, Sangkat Khmuonh, Khan Sen Sok, Phnom Penh, Cambodia.

O-8 ឯកសារបច្ចេកទេស (1~15)

O-3 លិខិតស្នើសុំផ្តល់សេវា (ច្បាប់ដើម) ១ច្បាប់ ហត្ថលេខាដោយម្ចាស់សំណង់/អ្នកសិក្សាគម្រោង

＊ចំពោះចំនួនទឹកប្រាក់កិច្ចសន្យា និងពេលវេលាបញ្ជាក់មានសរសេរនៅក្នុង [លិខិតឆ្លើយតបទៅនឹងការផ្តល់សេវា]។

⑤ នៅពេលដែលមកដល់ក្រុមហ៊ុន យើងនឹងចេញវិក្កយបត្រស្នើសុំការបង់ប្រាក់ និងលិខិតទទួលឯកសារ O-8។

- សូមធ្វើការបង់ប្រាក់ថ្លៃសេវាក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការ។
- បន្ទាប់ពីពិនិត្យពីការបង់ប្រាក់រួច យើងនឹងចេញវិក្កយបត្រជូន ហើយនឹងជូនដំណឹងអំពីការបានទទួលប្រាក់ទៅលោកអ្នកវិញតាមរយៈតេលេក្រាម។

⑥ បន្ទាប់ពីទទួលបានទទួលប្រាក់ថ្លៃសេវារួចរាល់ យើងនឹងចាប់ផ្តើមចុះកិច្ចសន្យា។

⑦ បន្ទាប់ពីយើងពិនិត្យមើលកិច្ចសន្យារួចរាល់ យើងនឹងជូនដំណឹងទៅលោកអ្នកតាមរយៈតេលេក្រាមដើម្បីមកទទួលកិច្ចសន្យាពីខាងក្រុមហ៊ុននៅ៣ថ្ងៃបន្ទាប់នៃថ្ងៃធ្វើការ។

⑧ ការចាប់ផ្តើមកិច្ចសន្យា/ការចាប់ផ្តើមការងារបញ្ជាក់

- កាលបរិច្ឆេទនៃការចាប់ផ្តើមការងារ គឺគិតពីថ្ងៃចុះកិច្ចសន្យា(ថ្ងៃទទួលបានប្រាក់ថ្លៃសេវា)។

⑨ បន្ទាប់ពីការងារបញ្ជាក់គម្រោងប្លង់ត្រូវបានបញ្ចប់ យើងនឹងជូនដំណឹងទៅអ្នកដូចខាងក្រោម។

- លិខិតជូនដំណឹងពីការបញ្ចប់ការងារ
- វិក្កយបត្រស្នើសុំការបង់ប្រាក់

＊សូមធ្វើការទូទាត់ប្រាក់ក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានឯកសារខាងលើ។

⑩ បន្ទាប់ពីពិនិត្យឃើញថាប្រាក់ត្រូវបានទូទាត់រួច យើងនឹងធ្វើការជូនដំណឹងទៅវិញតាមរយៈតេលេក្រាមអំពីការមកទទួល ឯកសាររបាយកាណ៍។ ដូចនេះសូមអញ្ជើញមកទទួលឯកសារពីខាងក្រុមហ៊ុននៅ៣ថ្ងៃបន្ទាប់នៃថ្ងៃធ្វើការ បន្ទាប់ពីការជូនដំណឹង ។

**កំណត់ចំណាំ**

＊ចំពោះការមកក្រុមហ៊ុនក្រៅពីចំណុចទី⑦・⑩ សូមធ្វើការណាត់ជួបនឹងកំណត់ថ្ងៃជាមុន។ ក្នុងករណីមិនមានការណាត់ជួបមុននោះទេ យើងខ្ញុំមិនទទួលជួបនោះឡើយ។



Address: Lot No. 2005, Office No. 515, 5th Floor, Street 307, Sangkat Khmuonh, Khan Sen Sok, Phnom Penh, Cambodia.

## កំណត់ចំណាំ

＊ការស្នើសុំគឺធ្វើដោយម្ចាស់សំណង់ ឬអ្នកដែលបានទទួលសិទ្ធិពីម្ចាស់សំណង់។ ចំពោះអ្នកផ្សេងទៀតគឺមិនអាចធ្វើការស្នើសុំបានឡើយ។

＊យើងមិនទទួលយកការបង់ថ្លៃសេវាផ្ទាល់នៅការិយាល័យឡើយ។

＊ក្នុងករណីដូចខាងក្រោម [ការផ្អាកការងារ/ការបញ្ឈប់កិច្ចសន្យា] នឹងត្រូវបានអនុវត្ត ហើយប្រាក់ដែលបង់រួចមិនត្រូវបានសងត្រឡប់ទៅវិញឡើយ។

① ក្នុងករណីកិច្ចសន្យាត្រូវបានលុបចោលដោយសារតែមូលហេតុរបស់ម្ចាស់សំណង់។ ចំពោះប្រាក់ដែលបានទូទាត់រួចលើកទីមួយបន្ទាប់ពីចុះកិច្ចសន្យានឹងមិនត្រូវបានសងត្រឡប់ទៅវិញឡើយ។

② ក្នុងករណីរយៈពេលនៃការទូទាត់ប្រាក់លើកទី២លើសពី៧ថ្ងៃនៃថ្ងៃធ្វើការ (កិច្ចសន្យានឹងត្រូវលុបចោល)។

③ ក្នុងករណីឯកសារ និងគម្រោងប្លង់សម្រាប់ការបញ្ជាក់ដែលបានដាក់មកមិនពិត (កិច្ចសន្យានឹងត្រូវបានលុបចោល)

④ ក្នុងករណីប្រសិនបើរកឃើញថាមានភាពមិនអនុលោម យើងខ្ញុំនឹងចេញ [លិខិតជូនដំណឹងពីភាពខ្វះខាត]។

⑤ ក្នុងករណីមិនមានការកែតម្រូវទៅតាមពេលវេលាដែលបានកំណត់ បន្ទាប់ពីថ្ងៃចេញ [លិខិតជូនដំណឹងអំពីភាពខ្វះខាត] យើងនឹងចេញ [លិខិតស្តីពីភាពមិនអនុលោម]។

⑥ ក្នុងករណីមិនមានការកែតម្រូវទៅតាមពេលវេលាដែលបានកំណត់ បន្ទាប់ពីថ្ងៃចេញ [លិខិតជូនដំណឹងអំពីភាពខ្វះខាត] [លិខិតបញ្ជាក់ពីអនុលោមភាព] នឹងត្រូវបានបញ្ជាក់ជាលិខិតមិនអនុលោមភាព។ ក្នុងករណីការបញ្ជាក់ជាភាពមិនអនុលោមក៏ដោយ ក៏តម្រូវអោយមានការបង់ប្រាក់ថ្លៃសេវាដែលនៅសល់ដែរ។

⑦ ក្នុងអំឡុងពេលការងារកែតម្រូវរបស់អតិថិជន គឺមិនរាប់បញ្ចូលពេលវេលាអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់ឡើយ។

## ក្នុងករណីមកដល់ក្រុមហ៊ុនដើម្បីធ្វើការពិភាក្សា និងសួរសំណួរ

ដើម្បីកាត់បន្ថយពេលវេលានៃការរង់ចាំនៅពេលដែលមកដល់ក្រុមហ៊ុនអោយមានរយៈពេលខ្លី យើងបានរៀបចំប្រព័ន្ធនិងរបៀបនៃការណាត់ជួបដើម្បីអោយការទទួលមានភាពរលូនផងដែរ។ ដូចសូមធ្វើការណាត់ជួបទៅតាមការណែនាំដូចខាងក្រោម។

យើងខ្ញុំមិនទទួលការសួរសំណួរតាមរយៈទូរស័ព្ទឡើយ។

① បន្ទាប់ពីបំពេញពត៌មានដែលត្រូវការក្នុងលិខិតណាត់ជួបរួច សូមផ្ញើរមកយើងខ្ញុំតាមរយៈតេលេក្រាម។

② យើងនឹងផ្ញើរលិខិតជូនដំណឹងអំពីការណាត់ជួបទៅអ្នកវិញតាមរយៈតេលេក្រាម។



Address: Lot No. 2005, Office No. 515, 5th Floor, Street 307, Sangkat Khmuonh, Khan Sen Sok, Phnom Penh, Cambodia.

※ ដោយសារតែយើងត្រូវមានការរៀបចំបុគ្គលិកដែលត្រូវជួបជាមួយអ្នកទៅតាមខ្លឹមសារនៃការពិភាក្សា ដូចនេះសូមសរសេរខ្លឹមសារនៃការណាត់ជួបអោយបានច្បាស់លាស់។

※ ដោយសារតែយើងមានការណាត់ជួបជាមួយនឹងអតិថិជនផ្សេងៗទៀត ដូចនេះការពិភាក្សាអាចមានរយៈពេលត្រឹម៥០នាទីប៉ុណ្ណោះ។

※ ក្នុងករណីប្រសិនបើកាលបរិច្ឆេទដែលលោកអ្នកដាក់មកយើងមិនអាចណាត់ជួប ឬបំពេញតាមសំណើររបស់លោកអ្នកបាន សូមមេត្តាស្នើការណាត់ជួបនៅថ្ងៃផ្សេងម្តងទៀត។

※ ចំពោះការណាត់ជួបដើម្បីពិភាក្សាឬសួរសំណួរ សូមស្នើការណាត់ជួបមកយើងខ្ញុំមុន៥ថ្ងៃនៃថ្ងៃធ្វើការ។



Address: Lot No. 2005, Office No. 515, 5th Floor, Street 307, Sangkat Khmuonh, Khan Sen Sok, Phnom Penh, Cambodia.